ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៣ អនុក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ឬរចំណាត់ថ្នាក់ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- លិខិតលេខ ៥៤២ MIH /២០២០ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ របស់ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ក្រសួងឧស្សាហកម្ម និងសិប្បកម្ម)
- លិខិតលេខ ១៨៥២ សជណ.ឌរ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ២៣៤៤ លស ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ ៩៣៧ សជណ.ផក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ១៨១ លស ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ ១០៥៨ សជណ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ៥០៦ លស ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ ១៦១០ សជណ.មយ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ២១០៦ កយ.រប/១៩ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ របស់ក្រសួងយុត្តិធម៌
- លិខិតលេខ ១២៧៥ សជណ.ផក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

## សម្រេច

**មាត្រា ១.-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវទីតាំងដូចខាងក្រោម÷

-ទីតាំងអតីតរោងចក្រយន្តសាស្ត្រទី៥ មានដីទំហំ៩ ២១៧ ម៉ែត្រក្រឡា ស្ថិតនៅសង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងទីតាំងអតីតរោងចក្រឥដ្ឋជ្រោយអំពិល មានដីទំហំ ៤៤ ២៧៤ ម៉ែត្រក្រឡា ស្ថិតនៅភូមិជ្រោយអំពិល សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។

-ទីតាំងពន្ធនាគារខេត្ត មានដីទំហំ ៤ ៦៧១ ម៉ែត្រក្រឡា ,ដីបម្រុងទុករដ្ឋបាលខេត្តកំពង់ឆ្នាំង ទំហំ ៤ ៣៥១ ម៉ែត្រក្រឡា និងដីតំបន់រដ្ឋបាលពន្ធនាគារ ទំហំ ៤ ៧២៥ ម៉ែត្រក្រឡា ស្ថិតនៅភូមិម៉ុងបារាំង សង្កាត់ប្អេរ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង។

-ទីតាំងអធិការដ្ឋាននគរបាល នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង មានដីទំហំ ៤០៥ ម៉ែត្រក្រឡា ស្ថិតនៅភូមិពោធិ៍ចិន្តាំ ឃុំស្វាយអន្ទរ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ។

-ទីតាំងមណ្ឌលសុខភាពប៉ោយប៉ែត១ មានដីទំហំ ៤ ០៧៥ ម៉ែត្រក្រឡា ស្ថិតនៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។

-ទីតាំងសាលាដំបូងខេត្តព្រះសីហនុ មានដីទំហំ ៤ ៣៤៨ ម៉ែត្រក្រឡា ស្ថិតនៅសង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

**មាត្រា២.-**

ការលុបទីតាំងដូចមានចែងក្នុងមាត្រា១ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវស្ថិតនៅក្រោមការចាត់ចែងតាមបែបបទ និងនីតិវិធីជាធរមាន ដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ចន្ទ ១៣រោច ខែចេត្រ ឆ្នាំជូតទោស័ក ព.ស. ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ